សុន្ទរកថារបស់**ឯកឧត្តម ម៉ាសាហ៊ីរ៉ូ គូរ៉ូគី** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព
របស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន

០៦ កញ្ញា ២០១២

**សូមគោរព ឯកឧត្តម អ៊ុំ ភូមិរ៉ូ អគ្គនាយករងអង្គការ CMAC!**
**សូមគោរព លោក យ៉ាស៊ូយូគិ តានីហ្គាវ៉ា ប្រធានតំណាងអង្គការ JMAS!**
**សូមគោរព អស់លោក លោកស្រី!**

- ខ្ញុំមានសេចក្តីសោមនស្សរីករាយដើម្បីចុះហត្ថលេខានៅថ្ងៃនេះលើកិច្ចសន្យាផ្តល់ជំនួយជាមួយ អង្គការសកម្មភាពកំចាត់មីនជប៉ុន(JMAS)សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន។

- ក្រោមកិច្ចខិតខំប្រឹងប្រែងជាច្រើនឆ្នាំរបស់រាជរដ្ឋាភិបាលកម្ពុជា និងជំនួយឧបត្ថម្ភនានាពីសហគមន៍អន្តរជាតិ ចំនួនជនរងគ្រោះដោយសារគ្រាប់មីននៅកម្ពុជាបានថយចុះជាលំដាប់។ រហូតមកដល់ពេលនេះ រដ្ឋាភិបាលជប៉ុនបាននិងកំពុងបន្តឧបត្ថម្ភគាំទ្រដល់សកម្មភាពកំចាត់មីននៅកម្ពុជាតាមរយៈជំនួយឧបត្ថម្ភ ក៏ដូចជាកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេស។ យ៉ាងណាមិញ បើទោះជាចំនួនជនរងគ្រោះបានបន្តថយចុះ ក៏នៅតែមានប្រជាជនជាង១០០នាក់រងគ្រោះដោយសារគ្រាប់មីនក្នុងឆ្នាំ២០១១ ជាពិសេសខេត្តបាត់ដំបងគឺជាតំបន់ដែលទទួលផលប៉ះពាល់ខ្លាំងជាងគេនោះមានជនរងគ្រោះស្មើនឹងមួយភាគបីនៃចំនួនជនរងគ្រោះទាំងអស់។ ដូច្នេះយើងនៅមានតំរូវការខ្ពស់សម្រាប់សកម្មភាពបោសសម្អាតមីនក្នុងខេត្តនេះ។

- ជាមួយនឹងជំនួយ៨៣៩,៣៦៣ដុល្លាអាមេរិកដែលរដ្ឋាភិបាលជប៉ុនផ្តល់ដល់អង្គការJMASនៅថ្ងៃនេះ អង្គការJMASនឹងធ្វើសកម្មភាពបោសសម្អាតមីនក្នុងភូមិជាមន្ត្រី ភូមិស្វាយស ភូមិប្រជៀវ និងភូមិជីសាង ស្រុករតនៈមណ្ឌលដែលត្រូវបានចាត់ទុកជាតំបន់មានមីនច្រើនជាងគេក្នុងខេត្តបាត់ដំបង។ ខ្ញុំបានដឹងថាពួកគេនឹងធ្វើការបោសសម្អាតមីនស្របតាមវិធីសាស្ត្រស្រាវជ្រាវបច្ចេកទេស និងស្រាវជ្រាវទូទៅដែលជាវិធីសាស្ត្រស្តង់ដាររបស់UN។ ដោយប្រើប្រាស់វិធីសាស្ត្រនេះ ពួកគេនឹងអាចធ្វើការបោសសម្អាតមីនបានឆាប់រហ័សជាងមុនដែលនឹងរួមចំណែកដល់ការធ្វើឲ្យសម្រេចផែនការរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងកាបោសសម្អាតមីនរហូតដល់ឆ្នាំ២០១៩ឲ្យបាន៦៥០គីឡូម៉ែត្រក្រឡាដូចដែលបានសន្យាក្នុងអនុសញ្ញាOtawa។

➢ ជាងនេះទៅទៀត ខ្ញុំបានទទួលពត៌មានថាជាផ្នែកមួយនៃការផ្ទេរបច្ចេកទេសក្នុងគម្រោងដូចគ្នាកាលពីឆ្នាំមុន JMASបានរៀបរៀង សៀវភៅណែនាំអំពីប្រតិបត្តិការ ដោយសហការជាមួយCMACដែលថ្នាក់ដឹកនាំរបស់CMACអាចយកទៅប្រើប្រាស់នៅទីលានបោសសម្អាតមីន។ តាមរយៈការណែនាំរបស់សៀវភៅនេះ ចំណេះដឹង និងជំនាញត្រូវបានផ្ទេរដោយផ្ទាល់ទៅដល់បុគ្គលិកម្នាក់ៗ។ យើងសង្ឃឹមយ៉ាងមុតមាំថាតាមរយៈការប្រើប្រាស់សៀវភៅណែនាំនេះបានត្រឹមត្រូវ យើងអាចផ្ទេរបច្ចេកទេសដើម្បីធ្វើផែនការបោសសម្អាតមីន ក៏ដូចជាអនុវត្តគម្រោងឲ្យកាន់តែមានប្រសិទ្ធភាពជាមួយនឹងវិធីសាស្ត្រដែលទើបចាប់ផ្តើមអនុវត្តថ្មីក្នុងឆ្នាំនេះ។

➢ តាមរយៈគម្រោងនេះ ប្រជាពលរដ្ឋប្រមាណប្រាំពាន់នាក់ក្នុងភូមិ៨នឹងត្រូវបានរំដោះចេញពីការគំរាមកំហែង និងការភ័យខ្លាចពីគ្រាប់មីន។ ខ្ញុំសង្ឃឹមថា គម្រោងនេះនឹងធ្វើឲ្យស្ថានភាពជីវិតរបស់ពួកគេមានលំនឹង ធ្វើឲ្យប្រសើរឡើងនូវបរិស្ថានរស់នៅ ក៏ដូចជាបន្តអភិវឌ្ឍន៍សហគមន៍ក្នុងតំបន់។

➢ ជាចុងក្រោយនេះ ជំនួយឧបត្ថម្ភរបស់ជប៉ុនសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុនត្រូវបានផ្តល់ជូនសម្រាប់គម្រោងអភិវឌ្ឍន៍ផ្នែកសង្គមកិច្ច និងសេដ្ឋកិច្ចដែលអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាលជប៉ុន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាកិច្ចសហប្រតិបត្តិការនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

សូមអរគុណ!